# Fever and Acetaminophen (Tylenol®)

## Harborview Medical Center

Children and Teens Clinic: (206) 744-3335

# ជំងឺគ្រុនក្ដៅនិងអាសុីតាមីណូហ្វិន (ថៃឡឺណុល)

## មន្ទីរពេទ្យហាបឺវីយូ

គ្លីនិកសម្រាប់ក្មេងតូច និងក្មេងជំទង់ (២០៦) ៧៤៤-៣៣៣៥

ឈ្មោះអ្នកជម្ងឺ: ____________________________________________

បើខ្លួនកូនរបស់លោកអ្នកហាក់បីដូចជាក្ដៅឧណ្ហៗ តាមការសន្មត់របស់គ្រូពេទ្យវាប្រហែលជាមានជម្ងឺ "គ្រុនក្ដៅ "លោកគ្រូពេទ្យនឹងស្ទង់កំដៅមើល ថាតើមាន "កម្ដៅ " ប៉ុន្មាននៅលើប្រដាប់ស្ទង់កម្ដៅ។ បើសិនជាប្រដាប់ស្ទង់បង្ហាញថា 100.4° អែហ្វ (38°C) នេះមានន័យថាកូននោះមានជម្ងឺ "គ្រុនក្ដៅ " ហើយខ្លួន របស់វាក្ដៅជាងធម្មតា។ មានន័យថាកូនក្មេងនេះមានជម្ងឺសឹងតែគ្រប់ពេល ពេលខ្លះក្មេងនេះ "ក្ដៅ " ខ្លួន បន្ទាប់ពីទទួលការចាក់ថ្នាំការពារ។ ពេលខ្លះខ្លួនវាហាក់បីដូចជាក្ដៅ ពីព្រោះវាលេងច្រើន ឬស្លៀកពាក់អាវ ច្រើនពេក ប៉ុន្តែវាមិនឈឺអ្វីទេ។

ការកើតជម្ងឺ "គ្រុនក្ដៅ "មិនមែនជាគ្រោះថ្នាក់អ្វីធ្ងន់ធ្ងរទេ "គ្រុនក្ដៅ " ប្រហែលជាអាចនឹងជួយទប់ទល់នឹងការ បង្ករោគ ទោះជាយ៉ាងនេះក៏ដោយ "គ្រុនក្ដៅ " ធ្វើឲ្យកូនក្មេងជាច្រើនធុញថប់មិនស្រួលចិត្តដែរ។ ហេតុដូច្នេះជាញឹកញាប់យើងព្យាបាលជម្ងឺ "គ្រុនក្ដៅ " ជាមួយនឹងថ្នាំឈ្មោះអាសុីតាមីណូហ្វិន ថៃឡឺណុលជាឈ្មោះសមញ្ញសម្រាប់ អាសុីតាមីណូហ្វិន។

ការដែលសំខាន់មិនមែននៅលើកម្ដៅមានកម្ពស់ប៉ុណ្ណាទេ ប៉ុន្តែស្ថិតនៅលើកូនរបស់លោកអ្នកមានសកម្មភាពយ៉ាងណាវិញ បើសិនជាកូននោះមាន "កម្ដៅ " 103° អែហ្វ ប៉ុន្តែវាមិនធ្វើទុក្ខ លេងច្រើនហើយញ៉ាំបាន កូននោះប្រហែលជាមិនអីទេ។ តែបើសិនជាកូនរបស់លោកអ្នកមានកម្ដៅតែ 101° អែហ្វ ប៉ុន្តែមានបញ្ហាក្នុងការដកដង្ហើម ឬងងុយដេកខ្លាំងមួម៉ៅ កូននោះប្រហែលជាឈឺខ្លាំងហើយ។

បន្ថែមពីលើថៃឡឺណុល ការខាងក្រោមនេះប្រហែលជាអាចជួយការក្ដៅខ្លួនរបស់កូនលោកអ្នក៖

- ស្លៀកពាក់ខោអាវស្ដើងៗឲ្យកូនលោកអ្នក រុំភួយស្ដើងឲ្យ។
- សាកល្បងឲ្យកូននោះញ៉ាំទឹកច្រើន។
- អាចដាក់កន្សែងជ្រលក់ទឹកត្រជាក់នៅលើថ្ងាស់កូននោះ **កុំឲ្យ**ប្រើទឹកត្រជាក់ខ្លាំង ទឹកកក ឬអាកុល។

សូមទូរស័ព្ទទៅគ្រូពេទ្យលោកអ្នក ***ភ្លាម*** បើសិនជាមានការដូចខាងក្រោមនេះ៖

- រោយក ឈឺក្បាល ឬភាំង។
- ធ្វើឲ្យត្រជាក់ ឬពិបាកក្នុងខ្លួន
- ងងុយគេងហួសហេតុ
- យំ ឬមួម៉ៅហួសហេតុ
- មានការពិបាក ឬឮសូរខ្យល់នៅពេលដកដង្ហើម
- ឡើងកន្ទួលព័ណ៌ស្វាយលើស្បែក
- កូនរបស់លោកអ្នកមានអាយុតិចជាង៣ខែ ហើយមានកម្តៅលើសពី 100.4° អែហ្វ (38°C)
- កូនលោកអ្នកមានជម្ងឺក្តៅខ្លួនលើសពីបីថ្ងៃ
- កូនរបស់លោកអ្នកមានការឈឺចាប់ ▯ទោះជាបានលេបថ្នាំថៃឡឺណុលហើយក៏ដោយ
- កូនរបស់លោកអ្នកហាក់បីដូចជាឈឺកាន់តែខ្លាំង ឬក៏លោកមានការបារម្ភ

នៅទីបំផុត **មិនត្រូវ** ឲ្យកូនរបស់លោកអ្នកលេបថ្នាំអាស្ពីរិនឡើយ លើកលែងតែគ្រូពេទ្យលោកអ្នកបង្គាប់ឲ្យលេប។ ថ្នាំថៃឡឺណុលបន្ថយរោគគ្រុនក្តៅដែលបណ្តាលមកពីការបង្ករោគ ឬមកពីការចាក់ថ្នាំការពារសម្រាប់កូនក្មេង វាក៏ជួយក្នុងការបន្ថយការឈឺចាប់តិចតួចដែលបណ្តាលមកពីជម្ងឺផ្តាសាយធម្មតា និងឈឺធ្មេញដែរ។

**ថ្នាំបន្តក់** (៨០មីលីក្រាម/០.៨មីលីលីត្រ)

កម្រិតថ្នាំ: ឲ្យ_____មីលីលីត្រ រាល់ ៤-៦ ម៉ោង នៅពេលណាដែលត្រូវការសម្រាប់បន្ថយការក្តៅខ្លួន ឬឈឺចាប់មិនត្រូវឲ្យលើសពី ៤ដងក្នុងរយៈពេល ២៤ម៉ោង។

**ថ្នាំលាយទឹក** (១៦០ មីលីក្រាម/៥មីលីលីត្រ)

កម្រិតថ្នាំ: ឲ្យ_____មីលីលីត្រ (______ស្លាបព្រាកាហ្វេពេញ) រាល់៤-៦ម៉ោង នៅពេលណាដែលត្រូវសម្រាប់បន្ថយការក្តៅខ្លួន ឬឈឺចាប់មិនត្រូវឲ្យលើសពី ៤ដងក្នុងរយៈពេល ២៤ ម៉ោង។

**ថ្នាំគ្រាប់សម្រាប់ទំពារ** (៨០មីលីក្រាម)

កម្រិតថ្នាំ: ឲ្យ_____គ្រាប់ រាល់៤-៦ម៉ោង នៅពេលណាដែលត្រូវការសម្រាប់បន្ថយការក្តៅខ្លួន ឬឈឺចាប់ មិនត្រូវឲ្យលើសពី ៤ដងក្នុងរយៈពេល ២៤ម៉ោង។

**ថ្នាំគ្រាប់កម្លាំងធម្មតា** (៣២៥មីលីក្រាម)

កម្រិតថ្នាំ: លេប_____គ្រាប់ រាល់៤-៦ម៉ោង នៅពេលណាដែលត្រូវការសម្រាប់បន្ថយការក្តៅខ្លួន ឬឈឺចាប់មិនត្រូវលេបលើសពី ១២គ្រាប់ក្នុងរយៈពេល ២៤ម៉ោង។

- *មិនត្រូវប្រើជាមួយនឹងថ្នាំដទៃទៀតដែលមានជាតិអាស៊ីតាមីណូហ្វិន (ថៃឡឺណុល)។*
- *ជៀសវាងគ្រឿងដែលមានជាតិស្រា*

បើសិនជាលោកមានសំណួរស្តីពីថ្នាំរបស់លោកអ្នក សូមទូរស័ព្ទទៅគ្លីនិកលេខ (២០៦) ៧៤៤-៣៣៣៥។